# សុន្ទរកថាស្វាគមន៍

របស់ ឯកឧត្តម **ប៊ុន ណារិទ្ធ** អគ្គនាយកអាជ្ញាធរអប្សរា

ថ្លែងក្នុងពិធីចុះហត្ថលេខាលើ អនុស្សរណៈនៃការយោគយល់ រវាងអាជ្ញាធរអប្សរា
និងសាជីវកម្មសំណង់ស៊ីវិលប្រទេសចិន

ស្តីពី

**«គម្រោងគ្រប់គ្រងធនធានដែលមានស្រាប់ សម្រាប់ការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរនិងតំបន់សៀមរាប»**

ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា

សៀមរាប ថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣

- *សូមគោរព ឯកឧត្តមបណ្ឌិតសភាចារ្យ **សុខ អាន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា*
- *សូមគោរព លោក Liu Zhiming ប្រធានសាជីវកម្មវិស្វកម្មសំណង់ស៊ីវិលប្រទេសចិន*
- *សូមគោរព ឯកឧត្តម Azedine Beschaouch លេខាធិការអចិន្ត្រៃយ៍វិទ្យាសាស្ត្រនៃគណៈកម្មការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ*
- *ឯកឧត្តម លោកជំទាវ លោក លោកស្រី ប្រិយមិត្តទាំងអស់ជាទីរាប់អាន!*

ជាបឋម តាងនាមអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅចំពោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ រវាងអាជ្ញាធរអប្សរានិងសាជីវកម្មសំណង់ស៊ីវិលប្រទេសចិន។

អគ្គនាយកដ្ឋានអាជ្ញាធរអប្សរាមានកិត្តិយស ដែលបានទទួល ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានអាជ្ញាធរអប្សរា អញ្ជើញចូលរួមជាអធិបតីដ៏ខ្ពង់ខ្ពស់ក្នុងពិធីនេះ ត្រូវនឹងឱកាសបិទសម័យប្រជុំពេញអង្គលើកទី៣៧ នៃគណៈកម្មាធិការបេតិកភណ្ឌពិភពលោកនៅតំបន់អង្គរ។ យើងកំពុងមានមោទនភាពបំផុត នៅពេលដែលព្រះរាជាណាចក្រកម្ពុជាបានទទួលធ្វើជាម្ចាស់ផ្ទះលើកទី១ នៃសម័យប្រជុំពេញអង្គគណៈកម្មាធិការបេតិកភណ្ឌពិភពលោក ដែលបានដំណើរការនៅរាជធានីភ្នំពេញចាប់ពីថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៣ ហើយមកបិទសម័យប្រជុំនៅល្ងាចថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០១៣ នៅរមណីយដ្ឋានអង្គរ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមអនុញ្ញាតរម្លឹកជូនត្រួសៗអំពីកាលបរិច្ឆេទសំខាន់ៗពាក់ព័ន្ធនឹងរមណីយដ្ឋានបេតិកភណ្ឌពិភពលោកអង្គរដូចតទៅៈ

- នៅខែធ្នូ ឆ្នាំ១៩៩២ រមណីយដ្ឋានអង្គរដែលមានផ្ទៃដី៤០១គម² ត្រូវបានចុះក្នុងបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់។
- នៅខែតុលា ឆ្នាំ១៩៩៣ គណៈកម្មការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរត្រូវបានបង្កើតឡើង។
- នៅខែកុម្ភៈ ឆ្នាំ១៩៩៥ អាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ ហៅថាអាជ្ញាធរ "អប្សរា" ត្រូវបានបង្កើតឡើង។
- នៅឆ្នាំ២០០៤ រមណីយដ្ឋានអង្គរត្រូវបានដកចេញពីបញ្ជីបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់។

ខ្ញុំសូមជម្រាបជូនថា នៅដំណាក់កាលដំបូងពីឆ្នាំ១៩៩២ រហូតដល់ឆ្នាំ២០០៤ការងារចម្បងនៅរមណីយដ្ឋានអង្គរគឺផ្តោតសំខាន់ទៅលើការទប់ស្កាត់ការលួចឆក់ប្លន់វត្ថុបុរាណ ការអភិរក្សនិងជួសជុលប្រាសាទដែលប្រឈមនឹងគ្រោះថ្នាក់ដួលរលំ ការការពារសន្តិសុខសុវត្ថិភាពនៅក្នុងរមណីយដ្ឋាន និងការរៀបចំរមណីយដ្ឋានសម្រាប់ទទួលភ្ញៀវទេសចរដែលចាប់ផ្តើមកើនចំនួនជាបណ្តើរៗ និងការផ្តល់ការងារជូនប្រជាពលរដ្ឋផងដែរ។

ដោយមានការគាំទ្រយ៉ាងពេញទំហឹងពីរាជរដ្ឋាភិបាល និងមានការចូលរួមសហការពីស្ថាប័នពាក់ព័ន្ធនានា ការងារការពារអភិរក្សអង្គរទទួលបានជោគជ័យគួរឲ្យកត់សំគាល់ បានលុបបំបាត់ស្ទើរតែទាំងស្រុងនូវការលួចឆក់ប្លន់វត្ថុបុរាណនៅក្នុងតំបន់អង្គរ រក្សាបានសន្តិសុខសុវត្ថិភាពក្នុងរមណីយដ្ឋានអង្គរ ជាពិសេសតាមរយៈគណៈកម្មការអន្តរជាតិសម្របសម្រួលកិច្ចគាំពារនិងអភិវឌ្ឍរមណីយដ្ឋានប្រវត្តិសាស្ត្រអង្គរ មានប្រទេសនិងអង្គការអន្តរជាតិជាង២០បានចូលមកជួយធ្វើការបណ្តុះបណ្តាលអ្នកជំនាញខ្មែរ ធ្វើការអភិរក្សនិងជួសជុលប្រាសាទដោយបានផ្តល់ទាំងធនធានហិរញ្ញវត្ថុនិងបច្ចេកទេសជាច្រើន ដូចជាប្រទេសបារាំង ប្រទេសជប៉ុន និងប្រទេសចិនជាដើម។ល។ ធ្វើឲ្យយើងអាចជួយសង្គ្រោះបានទាន់ពេលវេលានូវប្រាសាទមួយចំនួនដែលប្រឈមនឹងគ្រោះថ្នាក់ដួលរលំ។ ផ្អែកលើជោគជ័យទាំងអស់នេះហើយ ទើបគណៈកម្មាធិការបេតិកភណ្ឌពិភពលោកសម្រេចដករមណីយដ្ឋានអង្គរចេញពីបញ្ជីរមណីយដ្ឋានបេតិកភណ្ឌពិភពលោកប្រឈមនឹងគ្រោះថ្នាក់នៅឆ្នាំ២០០៤។

ចាប់តាំងពីពេលនោះមក អាជ្ញាធរអប្សរាមានបេសកកម្មថ្មីទៀតបន្ថែមលើបេសកកម្មដែលបានអនុវត្តកន្លងមក គឺត្រូវយកចិត្តទុកដាក់អំពីការអភិវឌ្ឍប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ និងការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ទឹក និងខ្យល់ជាដើមឲ្យបានល្អប្រសើរ ការអភិវឌ្ឍទេសចរណ៍ប្រកបដោយចីរភាព និងការអភិវឌ្ឍសហគមន៍ប្រជាពលរដ្ឋរស់នៅក្នុងតំបន់អង្គរ។ ក្នុងទិសដៅនេះហើយ ដែលអាជ្ញាធរអប្សរាបានកែសម្រួលរចនាសម្ព័ន្ធការងាររបស់ខ្លួនឡើងវិញដោយបង្កើតនាយកដ្ឋានថ្មីមួយចំនួនទៀតដូចជា នាយកដ្ឋានគ្រប់គ្រងទឹក នាយកដ្ឋានគ្រប់គ្រងព្រៃឈើ-ទេសភាពវប្បធម៌-និងបរិស្ថាន នាយកដ្ឋានអភិវឌ្ឍកសិកម្មនិងសហគមន៍ជាដើម។ ការងារលេចធ្លោដែលអាជ្ញាធរអប្សរាសម្រេចបានថ្មីៗនេះ គឺការគ្រប់គ្រងទឹកនៅតំបន់សៀមរាប-

អង្គរ ដោយបានរកឃើញនិងបានស្តារប្រព័ន្ធធារាសាស្ត្របុរាណសម័យអង្គរឲ្យដំណើរការឡើងវិញជាបណ្តើរៗ និងបានបញ្ចៀសទឹកជំនន់មិនឲ្យជន់លិចរមណីយដ្ឋានអង្គរ និងក្រុងសៀមរាបដោយជោគជ័យនៅឆ្នាំ២០១២ ផ្ទុយស្រឡះពីបណ្តាឆ្នាំមុនៗ ដែលតំបន់ទាំងពីរតែងទទួលរងគ្រោះមហន្តរាយដោយសារទឹកជំនន់រដូវវស្សា។

ការចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ ស្តីពី "គម្រោងគ្រប់គ្រងធនធានដែលមានស្រាប់ សម្រាប់ការអភិរក្សនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅរមណីយដ្ឋានអង្គរ និងតំបន់សៀមរាប" នៅពេលនេះ គឺដើម្បីបង្កលទ្ធភាពពង្រីកគម្រោងរបស់អាជ្ញាធរអប្សរាឲ្យកាន់តែមានប្រសិទ្ធភាពនិងមានចីរភាពថែមទៀត សម្រាប់ការអភិរក្សនិងការអភិវឌ្ឍនៅរមណីយដ្ឋានអង្គរ និងតំបន់ទាំងឡាយដែលពាក់ព័ន្ធ ជាពិសេសតំបន់ភ្នំគូលែនដែលជាប្រភពទឹកដ៏សំខាន់សម្រាប់ទ្រទ្រង់តំបន់ប្រាសាទអង្គរ និងសម្រាប់ការប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងខេត្តសៀមរាប ហើយតំបន់នេះក៏ជារមណីយដ្ឋានវប្បធម៌ ប្រវត្តិសាស្ត្រ និងជាប្រភពកំណើតនៃចក្រភពខ្មែរដែលមានប្រាង្គប្រាសាទ ចម្លាក់ និងសម្បត្តិវប្បធម៌ដ៏មានតម្លៃជាច្រើនទៀតនិងមានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធនឹងរមណីយដ្ឋានអង្គរ ដែលកំពុងរងការកាប់បំផ្លាញព្រៃឈើយ៉ាងធ្ងន់ធ្ងរគួរឲ្យបារម្ភ។

នៅទីអវសាននេះ ខ្ញុំសូមថ្លែងអំណរគុណដ៏ជ្រាលជ្រៅបំផុតចំពោះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តទាំងអស់ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួមក្នុងពិធីដ៏មានអត្ថន័យនេះ និងសូមគោរពជូនពរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ឯកឧត្តម លោកជំទាវ លោក លោកស្រី និងប្រិយមិត្តទាំងអស់ សូមទទួលបាននូវពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណ សុខ ពល កុំបីឃ្លៀងឃ្លាតឡើយ។

*សូមអរគុណ!*